ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមលេខាធិការ នៃក្រុមជំនួយការក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសម្រេច លេខ ២៩ សសរ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីសម្រេច លេខ ៤៩ សសរ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលេខាធិការ នៃក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមលេខាធិការ នៃក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម **រាជ សុភន្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | ជាប្រធាន |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ២ | លោកជំទាវ | **ឡាយ អូនរី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | ជាអនុប្រធាន |
| ៣ | លោក | **ប៊ុត ឌិ** | ប្រធាននាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច | ជាអនុប្រធានប្រចាំការ |
| ៤ | លោក | **ស៊ុន ឈុនហៀង** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌនិងខេត្ត | ជាសមាជិក |
| ៥ | លោក | **ហាឡេ វណ្ណៈ** | អនុប្រធាននាយកដ្ឋាននីតិកម្មអប់រំ និងស្ថានីតិសម្បទា | ជាសមាជិក |
| ៦ | លោក | **កៅ ម៉ុនសុខ** | អនុប្រធាននាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច | ជាសមាជិក |
| ៧ | លោក | **គិន តុណ្ណា** | អនុប្រធាននាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច | ជាសមាជិក |
| ៨ | លោក | **មុំ សុខន** | អនុប្រធាននាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច | ជាសមាជិក |
| ៩ | លោក | **ឡាយ ម៉ុណ្ណារិទ្ធ** | អនុប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល | ជាសមាជិក |
| ១០ | លោក | **ម៉ែត ចាន់ធី** | ប្រធានការិយាល័យ ទិន្នន័យ នាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ១១ | លោក | **ស៊ុយ សែនសីហៈ** | អនុប្រធានការិយាល័យន/ដកិច្ចការរដ្ឋបាល រាជធានី ខណ្ឌនិងខេត្ត | ជាសមាជិក |
| ១២ | លោក | **ម៉ុល មីនា** | អនុប្រធានការិយាល័យ នាយកដ្ឋានកិច្ចការរដ្ឋបាលនិងសរុប | ជាសមាជិក |
| ១៣ | លោក | **ម៉ា និរិទ្ធ** | ជំនួយការ **ឯកឧត្តម ឌី ច័ន្ទ្រផល** រដ្ឋលេខាធិការ | ជាសមាជិក |
| ១៤ | លោក | **ស៊ឹម ជឿន** | ជំនួយការ **ឯកឧត្តម ឌី ច័ន្ទ្រផល** រដ្ឋលេខាធិការ | ជាសមាជិក |
| ១៥ | លោក | **រស់ ភា** | មន្ត្រីអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ១៦ | លោក | **សុខ ដារ៉ា** | មន្ត្រីនាយកដ្ឋានសុចរិតភាពនិងអភិបាលកិច្ច | ជាសមាជិក |
| ១៧ | កញ្ញា | **ចៅ ប្រត្យក្សសុវណ្ណៈ** | មន្ត្រីអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ១៨ | លោក | **ម៉ា តារ៉ា** | មន្ត្រីអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ១៩ | លោកស្រី | **ចៅ ប្រត្យក្សរតនៈ** | មន្ត្រីអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ២០ | លោក | **ចាន់ ម៉េង** | មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌ និងខេត្ត | ជាសមាជិក |
| ២១ | លោក | **អ៊ុន សារឿន** | មន្ត្រីអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២២ | លោក | **ហ៊ាញ ម៉ុណ្ណា** | មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |

**ប្រការ ២._**

ក្រុមលេខាធិការ ជាសេនាធិការឲ្យក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាននិងមានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- ទទួលរបាយការណ៍ក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានរាជធានី ខេត្ត ដើម្បីបូកសរុបធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដាក់ជូនក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិដើម្បីពិនិត្យ និងសម្រេច



www.pheakdeylaw.com

- បូកសរុបរបាយការណ៍ និងវាយតម្លៃអំពីបញ្ហាប្រឈមផ្សេងៗ ក្នុងសកម្មភាពការងារចុះមូលដ្ឋានរបស់ក្រុមការងារថ្នាក់ជាតិ
- រៀបចំកិច្ចការប្រជុំ របៀបវារៈជាទៀងទាត់តាមការកំណត់
- រៀបចំគ្រប់គ្រងលិខិតរដ្ឋបាល សេចក្ដីសម្រេច និងឯកសារនានារបស់ក្រុមការងារថ្នាក់ជាតិ
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពី **ឯកឧត្តម ប្រធានក្រុមជំនួយការ** នៃក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាន។

**ប្រការ ៣.–**

ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ២ ប្រធានក្រុមលេខាធិការ ត្រូវសុំយោបល់ជាប្រចាំពីប្រធានក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ។ ប្រធានក្រុមលេខាធិការមានសិទ្ធិចាត់ចែងប្រគល់ភារកិច្ចដល់អនុប្រធាន និងសមាជិកក្រុមការងារ ព្រមទាំងកោះប្រជុំតាមការចាំបាច់។

**ប្រការ ៤.–**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានឈ្មោះ ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៧*

**ត.បនាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com